

# សុភី និងសុភាព

Komar Rien Komar Cheh, Sou Kimsan

Sou Kimsan

កុមាររៀន កុមារចេះ

Let's Read
The Asia Foundation



រៀងរាល់ម៉ោង សុភី និងសុភាព តែងជជែកគ្នាលេង
ពីនេះពីនោះ។



រៀងរាល់ព្រឹកព្រលឹម សុភីនិងសុភាពតែងជួយការងារឪពុកម្តាយ។



រៀងរាល់ព្រឹក សុភី និងសុភាព តែងញ៉ាំអាហារពេលព្រឹក
ជាមួយគ្នា។



រៀងរាល់ព្រលប់ សុភី និងសុភាពតែងរំលឹកមេរៀនជាមួយគ្នា។



រៀងរាល់យប់ សុភី និងសុភាពតែងអានរឿងនិទានមុន
ចូលដំណេក។



រៀងរាល់ថ្ងៃ សុភី និងសុភាពតែង ជួយគ្នាទៅវិញទៅមក។



រៀងរាល់ថ្ងៃ ឪពុកម្ដាយតែងនិយាយសរសើរសុភី និងសុភាព។



រៀងរាល់ខែ សុភី និងសុភាព តែងអួតប្រាប់ពុកម៉ែអំពីមេរៀននៅសាលា។



រៀងរាល់ឆ្នាំ សុភី និងសុភាព តែងបានរៀនឡើងថ្នាក់។



រៀងរាល់ឆ្នាំ ពុកម៉ែតែងជូនសុភី និងសុភាពដើរលេងនៅទីនេះ ទីនោះ។



គ្រប់ពេលវេលា សុភី និងសុភាព តែងរៀន និងលេងជាមួយគ្នា។



គ្រប់ពេលវេលា សុភី និងសុភាព តែងជួយការងារពុកម៉ែ ជាមួយគ្នា។ មិនចេះឈ្លោះប្រកែកគ្នា។



**សំណួរ**

១. តើនៅរៀងរាល់ព្រឹកព្រលឹម សុភី និងសុភាពតែងធ្វើអ្វី?

២. តើសុភី និងសុភាពតែងរំលឹកមេរៀនជាមួយគ្នានៅពេលណា?

៣. តើកូនដឹងទេថា ហេតុអ្វីបានជាឪពុកម្តាយរបស់សុភី និងសុភាពសរសើរពួកគេទាំងពីរនាក់?

៤. តើកូនចេះស្រឡាញ់បងប្អូនដែរឬទេ? តើកូនធ្លាប់ធ្វើអ្វីខ្លះជាមួយបង ឬប្អូនរបស់កូន?

## Brought to you by

The Asia Foundation

Let’s Read is an initiative of The Asia Foundation’s Books for Asia program that fosters young readers in the Asia-Pacific.
booksforasia.org
To read more books like this and get further information about this book, visit letsreadasia.org

**Original Story**

*សុភី និងសុភាព*, Author: Komar Rien Komar Cheh, Sou Kimsan.
Illustrator: Sou Kimsan
កុមាររៀន កុមារចេះ. Published by The Asia Foundation - Let’s Read,
https://www.letsreadasia.org/ © The Asia Foundation - Let’s Read.

Translations: © The Asia Foundation, 2020.